# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភាប្រចាំខែវិច្ឆិកា ឆ្នាំ២០២២

នៅក្នុងខែវិច្ឆិកា ឆ្នាំ២០២២នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចដូចតទៅ៖

## ១-សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា

### ១.១-សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា

#### ១.១.១-បដិសណ្ឋារកិច្ចឡៀវជាតិ-អន្តរជាតិ

-បានអនុញ្ញាតជូនឯកឧត្តម **Jagdeep Dhankhar** អនុប្រធានាធិបតី នៃសាធារណរដ្ឋឥណ្ឌា និងជាប្រធានព្រឹទ្ធសភា (RAJYA SABHA) និងគណៈប្រតិភូ ចូលជួបសម្តែងការគួរសម និងសវនាការ នៅវិមានព្រឹទ្ធសភា

-បានអនុញ្ញាតជូនឯកឧត្តម **Rachid Talbi EL Alami** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រម៉ារ៉ុក ចូលជួបសម្តែងការគួរសម និងសវនាការ នៅវិមានព្រឹទ្ធសភា

-បានអនុញ្ញាតជូនលោកជំទាវ **Sahiha Ali Gizi Gafarova** ប្រធានសភា នៃសាធារណរដ្ឋអាស៊ែបៃហ្សង់ ចូលជួបសម្តែងការគួរសម និងសវនាការ នៅវិមានព្រឹទ្ធសភា

-បានអនុញ្ញាតជូនឯកឧត្តមបណ្ឌិត **សាយសំផន ភូមិវិហាន** (Saysomphone PHOMVIHANE) ប្រធានរដ្ឋសភា នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ចូលជួបសម្តែងការគួរសម និងសវនាការ នៅវិមានព្រឹទ្ធសភា

-បានអនុញ្ញាតជូនឯកឧត្តម **វឿង ឌីញហ្វេ** (VUONG DINH HUE) ប្រធានរដ្ឋសភា នៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងគណៈប្រតិភូ ចូលជួបសម្តែងការគួរសម និងសវនាការ នៅវិមានព្រឹទ្ធសភា

-បានអនុញ្ញាតជូនឯកឧត្តម **ផាម មិញជីញ** (Pham Minh Chin) នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងគណៈប្រតិភូ ចូលជួបសម្តែងការគួរសម នៅវិមានព្រឹទ្ធសភា។



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

១.១.២-សកម្មភាពចុះមូលដ្ឋាន

-បានអញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខមន្ត្រី អាជ្ញាធរ និងកងកម្លាំងប៉ុស្តិ៍នគរបាល នៅខេត្តពោធិ៍សាត់

-បានអញ្ជើញសួរសុខទុក្ខលោកជំទាវកិត្តិនីតិកោសលបណ្ឌិត **ទី បូរ៉ាស៊ី** ប្រធានគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន នៃព្រឹទ្ធសភា នៅភូមិតាព្រហ្ម សង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

១.១.៣-សកម្មភាពចូលរួមពិធីផ្សេងៗ

-បានអញ្ជើញថ្លែងសុន្ទរកថាបើកមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ (AIPA-៤៣) ក្រោមមូលបទ " បោះជំហានជាមួយគ្នា ដើម្បីចីរភាព បរិយាបន្ន និងភាពធន់របស់អាស៊ាន" នៅសណ្ឋាគារសុខាភ្នំពេញ

-បានអញ្ជើញចូលរួមព្រះរាជកម្មពិធី " ១០០ព្រះវស្សា នៃព្រះបិតាឯករាជ្យជាតិដែលប្រព្រឹត្តទៅក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល នៅសាលមហោស្រពចតុមុខមង្គល

-បានអញ្ជើញជាគណៈអធិបតីដង្ហែព្រះរាជដំណើរ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ស្តេចយាងជាព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតក្នុងព្រះរាជពិធីបុណ្យខួបអនុស្សាវរីយ៍ លើកទី៦៩ នៃទិវាបុណ្យឯករាជ្យជាតិ ៩វិច្ឆិកា និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ ឆ្នាំ២០២២ នៅវិមានឯករាជ្យ

-បានអញ្ជើញជាគណៈអធិបតីដង្ហែព្រះរាជដំណើរ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ស្តេចយាងជាព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់បំផុត ក្នុងព្រះរាជពិធីពន្លត់ទៀនជ័យ នៅវិមានឯករាជ្យ

-បានអញ្ជើញជាកិត្តិយសក្នុងព្រះរាជពិធីលៀងសាយភោជន៍ ថ្វាយព្រះចៅស៊ុលតង់ HAJI HASSANAL BOLKIAH ព្រះមហាក្សត្រ នៃប្រទេសព្រុយណេ និងព្រះរាជគណៈប្រតិភូ រៀបចំឡើងដោយ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅព្រះរាជដំណាក់សិរីមង្គល ព្រះបរមរាជវាំង

-បានរៀបចំពិធីលៀងសាយភោជន៍ជូន ឯកឧត្តម **វឿង ឌីញហ្វេ** (VUONG DINH HUE) ប្រធានរដ្ឋសភា និងគណៈប្រតិភូ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម នៅអគារវឌ្ឍនៈ រាជធានីភ្នំពេញ។

**១.១.៤-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១៦ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១៤ច្បាប់។

## ១.២ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ុម កា អនុប្រធានទី១ ព្រឹទ្ធសភា

**១.២.១-សកម្មភាពចូលរួមពិធីផ្សេងៗ**

-បានអញ្ជើញចូលរួមព្រះរាជកម្មពិធី " ១០០ព្រះវស្សា នៃព្រះបិតាឯករាជ្យជាតិដែលប្រព្រឹត្តទៅក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល នៅសាលមហោស្រពចតុមុខមង្គល

-បានអញ្ជើញចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីប្រទានភ្លើងជ័យ និងពន្លត់ភ្លើងជ័យក្នុងឱកាសបុណ្យខួបអនុស្សាវរីយ៍លើកទី៦៩ នៃទិវាបុណ្យឯករាជ្យជាតិ ៩វិច្ឆិកា និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទឆ្នាំ២០២២ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជាជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅវិមានឯករាជ្យ។

## ១.៣ ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា

**១.៣.១-បដិសណ្ឋារកិច្ចឡៃជាតិ-អន្តរជាតិ**

-បានទទួលជួបពិភាក្សាការងារជាមួយឯកឧត្តម **Konstantin Kosachev** អនុប្រធានក្រុមប្រឹក្សាសហព័ន្ធ និងជាប្រធានគណៈប្រតិភូ នៃសហព័ន្ធរុស្ស៊ី ក្នុងឱកាសដែលឯកឧត្តមដឹកនាំគណៈប្រតិភូមកចូលរួមមហាសន្និបាតអន្តរសភាអាយប៉ា លើកទី៤៣ នៅវិមានព្រឹទ្ធសភា

-បានអញ្ជើញជាអធិបតីក្នុងពិធីលៀងសាយភោជន៍ជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា រដ្ឋសភា បណ្តាប្រទេសសមាជិកអាយប៉ា និងអ្នកអង្កេតការណ៍ជាតិ-អន្តរជាតិ នៅសណ្ឋាគារសុខាភ្នំពេញ។

១.៣.២-សកម្មភាពចុះមូលដ្ឋាន

-បានអនុញ្ញាតឱ្យក្រុមការងារដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តទៅពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋចំនួន២៦០នាក់ នៅឃុំព្រែកក្មេង ស្រុកល្វាឯម ខេត្តកណ្តាល

-បានចាត់ឱ្យក្រុមការងារចុះសួរសុខទុក្ខ និងនាំយកថវិកាមួយចំនួនជូនឯកឧត្តម **ញៀន ភៀន** រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា ដែលមានជំងឺស្ទះសរសៃឈាមខួរក្បាល និងកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យជោរ៉ៃភ្នំពេញ។

១.៣.៣-សកម្មភាពចូលរួមពិធីផ្សេងៗ

-បានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភាថ្វាយកម្រងផ្កា និងគោរពព្រះវិញ្ញាណក្ខន្ធបុព្វការីជន ក្នុងឱកាសនៃទិវាបុណ្យឯករាជ្យជាតិ ៩វិច្ឆិកា និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ ឆ្នាំ២០២២ នៅវិមានឯករាជ្យ

-បានអញ្ជើញចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីប្រទានភ្លើងជ័យ និងពន្លត់ភ្លើងជ័យក្នុងឱកាសបុណ្យខួបអនុស្សាវរីយ៍លើកទី៦៩ នៃទិវាបុណ្យឯករាជ្យជាតិ ៩វិច្ឆិកា និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ ឆ្នាំ២០២២ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅវិមានឯករាជ្យ

-បានអញ្ជើញអមដំណើរសម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភាអញ្ជើញសួរសុខទុក្ខលោកជំទាវកិត្តិនីតិកោសលបណ្ឌិត **ទី បូរ៉ាស៊ី** ប្រធានគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន នៃព្រឹទ្ធសភា នៅភូមិតាព្រហ្ម សង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ

-បានអនុញ្ញាតឱ្យក្រុមគ្រូពេទ្យឯកទេសត្រចៀកមកពីអង្គការហ្វេបកម្ពុជា ពិនិត្យ និងព្យាបាលជំងឺជូនជំនួយការ មន្ត្រីរាជការដែលបម្រើការងារនៅខុទ្ទកាល័យថ្នាក់ដឹកនាំព្រឹទ្ធសភា

-បានអញ្ជើញជាកិត្តិយសក្នុងពិធីបើក និងបិទកីឡាជាតិលើកទី៣ ឆ្នាំ២០២២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** នៅពហុកីឡដ្ឋានជាតិមរតកតេជោ រាជធានីភ្នំពេញ។

-បានអញ្ជើញដឹកនាំក្រុមសមាជិកាព្រឹទ្ធសភា រៀបចំពិធីដាល់អំបុក អកអំបុក និងបណ្តែតប្រទីប ដើម្បីអបអរសាទរក្នុងឱកាសនៃព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប

និងសំពះព្រះខែ នៅសង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ។

**១.៣.៤-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន២៤ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១៥ច្បាប់។

## ២.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា

សមាជិកព្រឹទ្ធសភា បានបំពេញការងារតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួន ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម៖

### ២.១ មុខងារតាមដានការអនុវត្តច្បាប់

-បានអញ្ជើញប្រជុំពិនិត្យពិភាក្សាការងារជាមួយប្រធានគណៈកម្មការទី១ គណៈកម្មការទី៣ រដ្ឋសភា, រដ្ឋមន្ត្រីក្រសួងបរិស្ថាន, ក្រសួងការពារជាតិ, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងគណៈកម្មាធិការសម្រាប់អភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ នៃក្រសួងមហាផ្ទៃ លើសំណើរបស់តំណាងសហគមន៍ជនជាតិភាគតិច ១៦អំបូរ ក្នុងការកែសម្រួលសេចក្តីព្រាងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ និងសេចក្តីព្រាងច្បាប់ស្តីពីព្រៃឈើ។

### ២.២ មុខងារតំណាង

-បានទទួលពាក្យបណ្តឹងចំនួន០៦ករណី បញ្ជូនពាក្យបណ្តឹងទៅក្រសួង រាជធានី ខេត្ត និងស្ថាប័នពាក់ព័ន្ធចំនួន០៧ករណី ឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន០៧ករណី កំពុងពិនិត្យសិក្សាចំនួន០៥ករណី ទទួលឯកសារជូនជ្រាបពីក្រសួង-ស្ថាប័នពាក់ព័ន្ធចម្លងជូនគណៈកម្មការចំនួន០១ករណី

-បានអញ្ជើញប្រជុំពិភាក្សាការងារជាមួយឯកឧត្តម **សរ ចំរុង** ប្រធានគណៈកម្មការទី១ រដ្ឋសភា, តំណាងអង្គការការីតាស និងមន្ត្រីពាក់ពន្ធ័ ស្តីពីការរៀបចំពិធីអបអរសាទរទិវាសិទ្ធិមនុស្សអន្តរជាតិ ខួបលើកទី៧៤ នៅវិមានព្រឹទ្ធសភា

-បានអញ្ជើញប្រជុំការងារគណៈកម្មការទ្រទ្រង់មូលនិធិគន្ធបុប្ផាកម្ពុជា នៃព្រឹទ្ធសភា នៅវិមានព្រឹទ្ធសភា

-បានអញ្ជើញប្រជុំដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងបទអន្តរាគមន៍ និងការងារផ្សេងៗ នៅសាលប្រជុំគណៈកម្មការទី២ នៃវិមានរដ្ឋសភា

-បានអញ្ជើញប្រជុំរៀបចំកំណត់បែងចែក ភារកិច្ចជូនថ្នាក់ដឹកនាំក្រុមចលនាស្ត្រីជាប្រធាន អនុប្រធានក្រុមការងារចលនាស្ត្រី រាជធានីភ្នំពេញ

-បានអញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តបេសកម្មមនុស្សធម៌ នៃប្រទេសបារាំង របស់ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ ព្រឹទ្ធសភា ចុះពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋក្រីក្រ នៅក្នុងវិទ្យាល័យស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ

-បានអញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តសម្តេចឧត្តមទេពញាណ **ហ៊ុន ណេង** ដឹកនាំដោយសាស្ត្រាចារ្យវិជ្ជបណ្ឌិត **យិន ស៊ីណាត** និងក្រុមគ្រូពេទ្យចំនួន៥៥នាក់ ចុះពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋសរុបចំនួន៣១៨នាក់ ព្រមទាំងឧបត្ថម្ភថវិកាជូនក្រុមគ្រូពេទ្យស្ម័គ្រចិត្តចំនួន៣០០,០០០រៀល

-បានអញ្ជើញនាំយកអំណោយដ៏ថ្លៃថ្លារបស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវជូនដល់មណ្ឌលកុមារកំព្រា និងមន្ទីរពេទ្យបង្អែកខេត្តកំពង់ស្ពឺ គិតជាទឹកប្រាក់សរុបចំនួន២៣,៧២៨,៨០០រៀល និងប្រាក់ដុល្លារចំនួន៣៨៧,១៥២ដុល្លារអាមេរិក

-បានអញ្ជើញចូលរួមវេទិកាជំរុញពាណិជ្ជកម្ម និងវិនិយោគកម្ពុជា-វៀតណាម ឆ្នាំ ២០២២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

-បានអញ្ជើញជាគណៈអធិបតីបើកសិក្ខាសាលាវាយតម្លៃហានិភ័យ នៃការកើតភាពមិនប្រក្រតីក្នុងវិស័យសុខាភិបាល រៀបចំឡើងក្រោមកិច្ចសហការរបស់ការិយាល័យអង្គការសហប្រជាជាតិប្រឆាំងបទឧក្រិដ្ឋ និងគ្រឿងញៀន និងអង្គភាពប្រឆាំងអំពើពុករលួយ នៅសណ្ឋាគារសូហ្វីតែល រាជធានីភ្នំពេញ

-បានអញ្ជើញចូលរួមជាគណៈអធិបតីបើកសិក្ខាសាលាស្តីពីបច្ចេកវិទ្យាទំនើបលើវិស័យចិញ្ចឹមសត្វ និងមហាសន្និបាតរបស់សមាគមអ្នកចិញ្ចឹមសត្វកម្ពុជា

-បានអញ្ជើញចូលរួមជាអធិបតីក្នុងវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សារាជធានីភ្នំពេញ អាណត្តិទី៣ ដើម្បីស្តាប់របាយការណ៍ ស្តីពីវឌ្ឍនភាពការងារវិនិយោគ៣ឆ្នាំរំកិល និងសកម្មភាពជាអាទិភាពរបស់ក្រុមប្រឹក្សារាជធានីភ្នំពេញ និងទទួលដោះស្រាយសំណូមពរជូនបងប្អូនប្រជាពលរដ្ឋ លើការងារសន្តិសុខសណ្តាប់ធ្នាប់ចរាចរណ៍ បង្ក្រាបទីតាំងល្បែងស៊ីសង និងកុងស៊ីបញ្ចាំខុសច្បាប់ ការពារសន្តិសុខសុវត្ថិភាពសាធារណៈសម្រាប់កិច្ចប្រជុំកំពូល ASEAN, AIPA ស្ថិតនៅមហោស្រពចេនឡា

ខណ្ឌទួលគោក រាជធានីភ្នំពេញ

-បានអញ្ជើញចូលរួមក្នុងពិធីបើក និងបិទសិក្ខាសាលា ស្ដីពីកិច្ចសន្ទនាអន្តរជំនឿសាសនា ដើម្បីសុខដុមនីយកម្មសាសនានៅកម្ពុជា ឆ្នាំ២០២២ ក្រោមប្រធានបទ "សាសនិកចូលរួមប្រឆាំងការជួញដូរមនុស្ស និងទាសភាពសម័យទំនើប" ក្រោមអធិបតីភាពឯកឧត្តម **ឈិត សុខុន** រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា នៅទីស្ដីការក្រសួងធម្មការ និងសាសនា

-បានអញ្ជើញចូលរួមពិធីចែកស្រូវពូជ ស្បៀងអាហារ និងថវិកាជូនប្រជាពលរដ្ឋដែលរងគ្រោះដោយជំនន់ទឹកភ្លៀង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចអគ្គមហាសេ-នាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

-បានអញ្ជើញចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីប្រទានភ្លើងជ័យ និងពន្លត់ភ្លើងជ័យក្នុងឱកាសបុណ្យខួបអនុស្សាវរីយ៍លើកទី៦៩ នៃទិវាបុណ្យឯករាជ្យជាតិ៩ វិច្ឆិកា និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ ឆ្នាំ២០២២ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត **ព្រះករុណា ព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅវិមានឯករាជ្យ

-បានអញ្ជើញចូលរួមព្រះរាជកម្មពិធី " ១០០ព្រះវស្សា នៃព្រះបិតាឯករាជ្យជាតិដែលប្រព្រឹត្តទៅក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត **ព្រះករុណា ព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និង**សម្ដេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្ដីថ្លៃថ្នូរ និងសុភមង្គល នៅសាលមហោស្រពចតុមុខមង្គល

-បានអញ្ជើញជាកិត្តិយសក្នុងពិធីបើកកីឡាជាតិលើកទី៣ ឆ្នាំ២០២២ ក្រោមអធិ-បតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** នៅពហុកីឡដ្ឋានជាតិមរតកតេជោ សង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

-បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីលៀងសាយភោជន៍ ជូនថ្នាក់ដឹកនាំបណ្ដាប្រទេសសមាជិកអាយប៉ា និងសភាអ្នកសង្កេតការណ៍ ភ្ញៀវជាតិ និងអន្តរជាតិ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសដែលសភានៃព្រះរាជាណាចក្រកម្ពុជាធ្វើជាម្ចាស់ផ្ទះ នៃមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ (ASEAN Inter-Parliamentary Assembly

(AIPA-43) នៅសណ្ឋាគារសុខារាជធានីភ្នំពេញ

-បានអញ្ជើញជាគណៈអធិបតី និងចូលរួមជាកិត្តិយសក្នុងពិធីផ្លូវការផ្សេងៗចំនួន ១៩០លើក

-ដោយឡែក សមាជិក សមាជិកាព្រឹទ្ធសភាបានអញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ ក្រុមគ្រូពេទ្យ អតីតមន្ត្រីរាជការជានិវត្តជន អតីតយុទ្ធជន ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីពង្រឹងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំអាណត្តិទី៥ នៅមូលដ្ឋាន ឈ្វេងយល់អំពីវឌ្ឍនភាពការងារ ការងារសន្តិសុខសណ្តាប់ធ្នាប់ ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ពិនិត្យហេដ្ឋារចនាសម្ព័ន្ធ សម្ពោធសមិទ្ធផលនានា ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា ជាពិសេស ពិនិត្យដំណើរការចុះឈ្មោះបោះឆ្នោត និងបានអំពាវនាវឱ្យប្រជាពលរដ្ឋអញ្ជើញទៅពិនិត្យ និងចុះឈ្មោះបោះឆ្នោតឱ្យបានគ្រប់ៗគ្នា នៅតាមមូលដ្ឋានរៀងៗខ្លួន ក្នុងភូមិភាគទាំង៨ ចំនួន៩០លើក។

## ២.៣ កិច្ចសហប្រតិបត្តិការអន្តរជាតិ

ការងារសហប្រតិបត្តិការអន្តរជាតិរបស់ព្រឹទ្ធសភា ជាពិសេស ទំនាក់ទំនងក្នុងកម្រិតតំបន់ និងអន្តរជាតិ សមាជិក សមាជិកាព្រឹទ្ធសភា បានចូលរួមយ៉ាងសកម្ម និងទទួលបានលទ្ធផលជាវិជ្ជមានដូចខាងក្រោម៖

-បានអញ្ជើញចូលរួមប្រជុំមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ (ASEAN Inter-Parliamentary Assembly) ក្រោមមូលបទ " បោះជំហានជាមួយគ្នាដើម្បីចីរភាពបរិយាបន្ន និងភាពធន់របស់អាស៊ាន " ក្រោមអធិបតីភាពសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និងជាប្រធានមហាសន្និបាតអន្តរសភាអាស៊ាន (AIPA) លើកទី ៤៣ នៅសណ្ឋាគារសុខាភ្នំពេញ

-បានអញ្ជើញចូលរួមប្រជុំក្រុមការងារទទួលបន្ទុកការសើរើលក្ខន្តិកៈ នៃសភាប្រើភាសាបារាំង និងចូលរួមមហាសន្និបាតប្រចាំឆ្នាំនៃបណ្តាញក្រុមសីលធម៌សមាជិកសភាប្រើភាសាបារាំង នៅសាធារណរដ្ឋបារាំង និងទស្សនកិច្ចការងារនៅសភាសហព័ន្ធវ៉ាល់ឡូនីព្រុចសែល ប្រទេសប៊ែលហ្សិក

-បានអញ្ជើញជួបសំដែងការគួរសម និងពិភាក្សាការងារជាមួយឯកឧត្តម Mohamad

SALHAJRI ឯកអគ្គរាជទូតគុយវ៉ែតទើបនឹងតែងតាំងថ្មី ប្រចាំព្រះរាជាណាចក្រកម្ពុជា ដើម្បីរឹតចំណងមិត្តភាព សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងសភា និងប្រជាជននៃប្រទេសទាំងពីរ កម្ពុជា-គុយវ៉ែត នៅស្ថានទូតគុយវ៉ែតប្រចាំព្រះរាជាណាចក្រកម្ពុជា

-បានអញ្ជើញចូលរួមក្នុងពិធីពិព័រណ៍ Walking through a songline រៀបចំឡើងដោយស្ថានទូតអូស្ត្រាលី ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាពឯកឧត្តម Hon Anthony Albanese នាយករដ្ឋមន្ត្រី នៃប្រទេសអូស្ត្រាលី និងស្ថាប័នពាក់ព័ន្ធនានា។

-បានអញ្ជើញចូលរួមកិច្ចប្រជុំក្រុមទទួលបន្ទុកសហប្រតិបត្តិការជាមួយសហភាពអន្តរសភាកម្ពុជា ដឹកនាំដោយ ឯកឧត្តម **កែប ជុតិមា** ប្រធានគណៈកម្មការទី៤ នៃរដ្ឋសភា ដើម្បីត្រៀមលក្ខណៈចូលរួមកិច្ចប្រជុំក្រុមទទួលបន្ទុកសហប្រតិបត្តិការជាមួយសហភាពអន្តរសភាលើកទី១០ នៅប្រទេសវៀតណាម នៅវិមានរដ្ឋសភា

-បានអញ្ជើញចូលរួមប្រជុំត្រៀមរៀបចំខ្លឹមសារ និងឯកសារពាក់ព័ន្ធនានា ដើម្បីទទួលគណៈប្រតិភូបេសកកម្មសុឆន្ទៈ នៃសភាប្រើប្រាស់ភាសាបារាំង ដែលគ្រោងមកទស្សនកិច្ច នៅព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាពឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ម៉ុម ជឹមហ៊ុយ** ប្រធានក្រុមសមាជិកព្រឹទ្ធសភា ទទួលបន្ទុកសហប្រតិបត្តិការជាមួយសភានិយាយភាសាបារាំង នៅវិមានព្រឹទ្ធសភា

-បានអញ្ជើញចូលរួមពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ស្ដីពីកិច្ចសហប្រតិបត្តិការរវាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាកម្ពុជា ជាមួយខុទ្ទកាល័យរដ្ឋសភាវៀតណាម ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា និងឯកឧត្តម **វឿង ឌីញហ្វេ** ប្រធានរដ្ឋសភាវៀតណាម នៅសាលប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា។+

ថ្ងៃ ចន្ទ ១២កើត ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០២២

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**កិត្តិសង្គហបណ្ឌិត ទេព ងន**

__ចម្លងជូន__

- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ជូនជ្រាបជាព័ត៌មាន)